ឯកសារសិក្សាគោលនយោបាយសង្ខេប
ការចេញផ្សាយលេខ០២ ឆ្នាំ២០១៨
ឯកសារបោះពុម្ពផ្សាយរបស់ ក្រុមប្រឹក្សាស្រាវជ្រាវអប់រំ
ការបោះផ្សាយនេះឧបត្ថម្ភដោយគម្រោងហិរញ្ញវត្ថុធនាគារអភិវឌ្ឍន៍អាស៊ី 2427 CAM (COL)

# ការរៀបចំផែនការ ការផ្ដល់ហិរញ្ញប្បទាន និងការអនុវត្តកម្មវិធីការសិក្សាពេញមួយជីវិត

## គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពពាក់ព័ន្ធនឹងការអប់រំប្រកបដោយគុណភាពនៅកម្ពុជា

សុខ សូត្រ[១], ពៅ វណ្ណា[២] និងសុក សេរី[៣]
[១]មហាវិទ្យាល័យអប់រំ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ [២]អង្គការ DVV International និង[៣]ការិយាល័យស្រាវជ្រាវ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
ទំនាក់ទំនងអ្នកនិពន្ធ។ សុក សេរី ការិយាល័យស្រាវជ្រាវ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ អ៊ីម៉ែល៖ sok.serey@rupp.edu.kh

## ខ្លឹមសារសំខាន់ៗ

- ការសិក្សាពេញមួយជីវិត បានក្លាយជាទស្សនៈថ្មីមួយ និងជាមាគ៌ាអប់រំសម្រាប់ប្រទេសកម្ពុជាដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) របស់ខ្លួននៅត្រឹមឆ្នាំ ២០៣០។ ការសិក្សាពេញមួយជីវិត រួមបញ្ចូលនូវការអប់រំក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការផងដែរ ទោះបីជាមនុស្សមួយចំនួនមានការយល់ច្រលំថាវាគ្រាន់តែជាផ្នែកមួយនៃការអប់រំក្រៅប្រព័ន្ធតែប៉ុណ្ណោះក៏ដោយ។
- នៅឆ្នាំ ២០១៦ ក្រសួងអប់រំ យុវជន និងកីឡា បានប្រើប្រាស់ទឹកប្រាក់ចំនួន ១៧៤ លានដុល្លារអាមេរិក៖ ថវិកាប្រចាំឆ្នាំសរុបចំនួន ៧៦.១% ដើម្បីសម្រេចបាននូវការអប់រំកម្រិតមូលដ្ឋានរយៈពេល ៩ ឆ្នាំ (សាលាបឋមសិក្សា ៤៨.៣% សាលាមធ្យមសិក្សាបឋមភូមិ ១៨.៧% និងមត្តេយ្យសិក្សា ៩.១%)។ សាលាមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា បានទទួលថវិកាក្នុងចំនួនប្រហាក់ប្រហែលគ្នា ដែលកម្រិតនីមួយៗទទួលបាន ៩.២%។ ទោះបីជាការអប់រំក្រៅប្រព័ន្ធនាពេលបច្ចុប្បន្ននេះ ត្រូវបានគេជឿជាក់ថានឹងចូលរួមចំណែកក្នុងការផ្ដល់នូវសកម្មភាពជាច្រើន ដើម្បីគាំទ្រដល់ការអប់រំពេញមួយជីវិតក៏ពិតមែន ក៏ប៉ុន្តែមានថវិកាប្រចាំឆ្នាំសរុបចំនួនត្រឹមតែ ២.៩% (ឬ ២២.១៦ លានដុល្លារអាមេរិក) ប៉ុណ្ណោះ ដែលត្រូវបានបែងចែកទៅដល់ផ្នែកនេះនៅក្នុងឆ្នាំ ២០១៦។
- ស្ថាប័នទ្វេភាគី ស្ថាប័នពហុភាគី និងអង្គការអន្តរជាតិនានា បានផ្ដល់មូលនិធិដល់សកម្មភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួននៅក្នុងស្រុក ដើម្បីគាំទ្រដល់វិស័យអប់រំពាក់ព័ន្ធនឹងគោលដៅ MDGs និងគោលដៅ SDGs។ កម្មវិធីសិក្សាពេញមួយជីវិត អាចនឹងប្រព្រឹត្តទៅបានល្អ ប្រសិនបើរដ្ឋាភិបាលកម្ពុជាបែងចែងថវិកាបន្ថែមសម្រាប់សកម្មភាពទាំងនេះ លើសពីចំនួនដែលមាននាពេលបច្ចុប្បន្ននេះសម្រាប់វិស័យអប់រំក្រៅប្រព័ន្ធ។

## ការសិក្សាពេញមួយជីវិតនៅក្នុងប្រព័ន្ធអប់រំកម្ពុជា

គោលគំនិតនៃការសិក្សាពេញមួយជីវិតនេះ នៅតែជាទស្សនៈថ្មីនៅឡើយសម្រាប់ភ្នាក់ងាររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនានានៅក្នុងប្រទេសកម្ពុជា។ ហេតុដូច្នេះ មានសកម្មភាពតិចតួចតែប៉ុណ្ណោះ ដែលត្រូវបានអនុវត្តដើម្បីរួមចំណែកទៅក្នុងទស្សនៈនេះ។ ការសិក្សាពេញមួយជីវិត បានក្លាយជាគោលដៅជាមូលដ្ឋានគ្រឹះមួយនៃគោលនយោបាយអប់រំ

នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ដោយគ្រប់គ្នាយល់ស្របថា ជាមធ្យោបាយមួយដើម្បីសម្រេចបាននូវការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងជាវិធីសាស្ត្រសម្រាប់លើកកម្ពស់សង្គមដោយឈរលើចំណេះដឹងជាមូលដ្ឋាន។ ការកើនឡើងនូវសារៈសំខាន់នៃការសិក្សាពេញមួយជីវិត ទាំងក្នុងគោលនយោបាយជាតិនិងអន្តរជាតិ នាំឱ្យមានតម្រូវការចាំបាច់ក្នុងការត្រួតពិនិត្យតាមដានយ៉ាងហ្មត់ចត់ និងល្អិតល្អន់បំផុតចំពោះអ្វីដែលអាចនឹងកើតមានឡើងពីកម្មវិធីនេះ។ ដើម្បីចាប់ផ្តើមប្រើប្រាស់ទស្សនៈនេះ យើងត្រូវតែយល់ដឹងអំពីការទទួលខុសត្រូវក្នុងការគ្រប់គ្រង ការផ្តល់ឱ្យ និងការគាំទ្រការសិក្សាពេញមួយជីវិត តាមរយៈឱកាសនៅក្នុងការបង្កើតការវិភាគ និងការអនុវត្តផ្ទាល់ខ្លួននៅក្នុងមជ្ឈដ្ឋានសេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា និងគោលនយោបាយដែលមានការប្រែប្រួលឥតឈប់ឈរ[1] ។ អតីតប្រធានប្រតិបត្តិអង្គការក្រៅរដ្ឋាភិបាលមួយដែលមានឈ្មោះថា អង្គការភាពជាដៃគូអប់រំកម្ពុជា (NEP) គឺជាបុគ្គលលេចធ្លោមួយរូប និងមានបទពិសោធន៍ច្រើនក្នុងការងារសង្គមស៊ីវិលពាក់ព័ន្ធនឹងវិស័យអប់រំ ហើយបានផ្តល់នូវទិដ្ឋភាពទូទៅខ្លីៗខ្លះអំពីថា តើទស្សនៈនៃការសិក្សាពេញមួយជីវិតនេះត្រូវបានបញ្ចូលទៅក្នុងប្រទេសកម្ពុជាយ៉ាងដូចម្តេច។

> *នៅអឺរ៉ុប ការសិក្សាពេញមួយជីវិតនេះ ត្រូវបានដាក់ឱ្យអនុវត្តជាយូរណាស់មកហើយនៅតាមបណ្តាប្រទេសមួយចំនួនដូចជាប្រទេសអាល្លឺម៉ង់ជាដើម។ ប្រជាជននៅទីនោះសិក្សារៀនសូត្រនៅតាមផ្ទះ ទីសាធារណៈ និងនៅការិយាល័យ។ ពួកគេចូលចិត្តការអាន។ ការសិក្សាពេញមួយជីវិត គឺជាទស្សនៈថ្មីមួយនៅក្នុងប្រទេសកម្ពុជា ហើយត្រូវបានគេស្គាល់ជាលើកដំបូងនៅពេលដាក់ឱ្យអនុវត្តគោលដៅ SDGs។ មុនឆ្នាំ២០១៥ ការសិក្សាពេញមួយជីវិត មិនត្រូវបានយកមកពិភាក្សា ឬជជែកវែកញែកឡើងនៅក្នុងប្រទេសកម្ពុជា ហើយការអប់រំក្រៅប្រព័ន្ធមានការពេញនិយមជាខ្លាំង។ មកដល់ឆ្នាំ ២០១៥ នៅទីក្រុងអ៊ីនឆន ប្រទេសកូរ៉េខាងត្បូង គេបានចាប់ផ្តើមជជែកពិភាក្សាអំពីការសិក្សាពេញមួយជីវិត។ ពីមុនមកដល់ពេលនេះ មានអង្គការក្រៅរដ្ឋាភិបាលតិចតួចប៉ុណ្ណោះដែលកំពុងធ្វើការងារពាក់ព័ន្ធនឹងការសិក្សាពេញមួយជីវិត ដូចជាអង្គការ DVV ជាដើម[2]។*

នៅឆ្នាំ២០១០ មន្ត្រីរាជការមកពីក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានបញ្ជូនទៅចូលរួមក្នុងការបណ្តុះបណ្តាលនៅប្រទេសអាល្លឺម៉ង់ ប្រទេសបែលហ្ស៊ិក និងប្រទេសហូឡង់។ បន្ទាប់ពីការបណ្តុះបណ្តាល ប្រតិភូកម្ពុជាបានជម្រាបជូនដំណឹងដល់ក្រសួងអប់រំ យុវជន និងកីឡា អំពីការសិក្សាពេញមួយជីវិតនេះ ប៉ុន្តែគ្មានចំណាត់ការណាមួយត្រូវបានធ្វើឡើងនៅពេលនោះទេ។ នៅខែតុលា ឆ្នាំ២០១៧ ប្រតិភូមកពីក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានបញ្ជូនទៅម្តងទៀតដើម្បីទទួលការបណ្តុះបណ្តាលស្តីពីការសិក្សាពេញមួយជីវិតនៅប្រទេសវៀតណាម។ នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០១៧ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំសិក្ខាសាលាជាលើកដំបូង ដោយមានការគាំទ្រពីអង្គការ UNESCO និងអង្គការ DVV។ ពួកគាត់ ជាអ្នកត្រួសត្រាយផ្លូវក្នុងការផ្តួចផ្តើមគំនិតអភិវឌ្ឍគោលនយោបាយស្តីពីការសិក្សាពេញមួយជីវិតនៅក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្ននេះ គោលនយោបាយស្តីពីការសិក្សាពេញមួយជីវិត ត្រូវបានធ្វើសេចក្តីព្រាង

---

[1] សាកលវិទ្យាធិការរងទទួលបន្ទុកផ្នែកស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

[2] អតីតប្រធានប្រតិបត្តិអង្គការក្រៅរដ្ឋាភិបាលមួយដែលមានឈ្មោះថា អង្គការភាពជាដៃគូកម្ពុជា (NEP) ទីក្រុងភ្នំពេញ។

និងរង់ចាំការអនុម័តសម្រេចដោយទីស្តីការគណៈរដ្ឋមន្ត្រី[3]។ កិច្ចប្រជុំជាន់ខ្ពស់រួមមួយ[4] ត្រូវបានស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅសណ្ឋាគារសូហ្វីតែល រាជធានីភ្នំពេញ ដែលនេះគឺជាជំហានដំបូងឆ្ពោះទៅរកការបង្កើតគោលនយោបាយសិក្សាពេញមួយជីវិតនៅក្នុងប្រទេសកម្ពុជា។ កិច្ចប្រជុំអញ្ជើញចូលរួមដោយអ្នកតំណាងមកពីបណ្តាក្រសួងនានា ស្ថាប័នអង្គការ UNESCO សម្រាប់ការសិក្សាពេញមួយជីវិត បណ្តាញក្រសួងអប់រំនៃប្រទេសជាសមាជិកអាស៊ាន (SEAMEO CELLL) និងអង្គការអន្តរជាតិ DVV ដើម្បីស្វែងរកការយល់ដឹងរួមគ្នាទៅលើការសិក្សាពេញមួយជីវិត និងខ្លឹមសាររបស់វាជាអន្តរជាតិ និងនៅក្នុងបរិបទកម្ពុជា ដើម្បីត្រៀមរៀបចំសម្រាប់ការបកប្រែពន្យល់ទៅក្នុងក្របខណ្ឌច្បាប់ថ្នាក់ជាតិ។ ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍បន្ថែមទៀតថា៖

> *គោលនយោបាយនេះ បានបង្កើតឡើងដោយមានការខិតខំប្រឹងប្រែង និងការគាំទ្រយ៉ាងពេញទំហឹងពីអង្គការ UNESCO បណ្តាញ SEAMEO CELLL អង្គការ DVV និងបណ្តាអង្គការជាតិ និងអន្តរជាតិផ្សេងទៀត ដែលអនុវត្តការងារដើម្បីគាំទ្រដល់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា។ មានបញ្ហាមួយចំនួនដែលអាចរាំងស្ទះដល់ការអនុវត្តការសិក្សាពេញមួយជីវិតនេះ បញ្ហាទាំងនោះរួមមានកម្មវិធីសិក្សា ផែនការយុទ្ធសាស្ត្រ និងយន្តការត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីត្រួតពិនិត្យផែនការយុទ្ធសាស្ត្រនេះ*[5]។

បើតាមប្រធានផ្នែកអប់រំរបស់អង្គការ UNESCO ប្រចាំនៅទីក្រុងភ្នំពេញ បានលើកឡើងថា "ការសិក្សាពេញមួយជីវិត គឺជាតម្រូវការរបស់ប្រទេសកម្ពុជា។ ទស្សនៈនេះ ត្រូវបានដាក់ឱ្យអនុវត្តតាំងពីឆ្នាំ១៩៧២ ប៉ុន្តែវានៅតែថ្មីស្រឡាងសម្រាប់ប្រទេសកម្ពុជានេះ។ ក្នុងនាមជាអ្នកកាន់សាសនាហិណ្ឌូម្នាក់ ... យើងចាំបាច់ត្រូវសិក្សាគម្ពីសាសនាហិណ្ឌូចាប់ពីពេលកើតដល់ស្លាប់។ ការសិក្សាអាចកើតមានគ្រប់ពេលវេលាទាំងអស់"[6]។ ប្រព័ន្ធអប់រំកម្ពុជា រួមមានការអប់រំក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ។ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ ត្រូវបានយកមកពិចារណាកាលពីកន្លងមកដែរ ក្រៅពីការអប់រំក្នុងប្រព័ន្ធ។ អតីតប្រធានប្រតិបត្តិអង្គការក្រៅរដ្ឋាភិបាលមួយឈ្មោះ អង្គការភាពជាដៃគូអប់រំកម្ពុជា (NEP) បានបង្ហាញថា ការសិក្សាពេញមួយជីវិត គឺមានលក្ខណៈទូលំទូលាយជាងការអប់រំក្រៅប្រព័ន្ធ។ ការសិក្សាពេញមួយជីវិត រួមមានការអប់រំក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ។ គ្រឹះស្ថាននានា អាចជួយលើកកម្ពស់ការទទួលបានចំណិន និងចំណេះដឹងអំពីបណ្តាសហគមន៍នៅតាមមូលដ្ឋាន ។ ការសិក្សាពេញមួយជីវិត អាចអនុវត្តបានល្អ នៅពេលដែលគ្រឹះស្ថាននានាបំពាក់សម្ភារៈបរិក្ខារបានល្អ។ សហគមន៍

---

[3] អតីតប្រធានប្រតិបត្តិអង្គការក្រៅរដ្ឋាភិបាលមួយដែលមានឈ្មោះថា អង្គការភាពជាដៃគូកម្ពុជា (NEP) ទីក្រុងភ្នំពេញ។

[4] សូមអានសេចក្តីលម្អិត៖ http://www.dvv-international.la/detail/news/the-first-step-towards-a-lifelong-learning-policy-in-cambodia/?tx_news_pi1%5Bcontroller%5D=News&tx_news_pi1%5Baction%5D=detail&cHash=53ec614f4df60bb47ac82ae3d32ab1e3

[5] អតីតប្រធានប្រតិបត្តិអង្គការក្រៅរដ្ឋាភិបាលដែលមានឈ្មោះថា អង្គការភាពជាដៃគូកម្ពុជា (NEP) ទីក្រុងភ្នំពេញ។

[6] ប្រធានផ្នែកអប់រំនៃអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃអង្គការសហប្រជាជាតិ (UNESCO) រាជធានីភ្នំពេញ។

នីមួយៗ មានតម្រូវការ និងការចង់បានផ្សេងៗគ្នា ដូច្នេះមជ្ឈមណ្ឌលអាចបំពេញការងារនៅក្នុងការចុះវាយតម្លៃលើតម្រូវការផ្នែកជំនាញ ដើម្បីកំណត់ពីតម្រូវការនៅតាមមូលដ្ឋាន[7] ។ ទន្ទឹមគ្នានេះដែរ ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡាបានផ្តល់មតិយោបល់ដូចខាងក្រោមថា៖

> *ការអប់រំក្រៅប្រព័ន្ធ គឺជាផ្នែកមួយនៃការសិក្សាពេញមួយជីវិត ប៉ុន្តែយើងនៅមានការយល់ច្រឡំគ្នា។ អ្នកដើរតួនាទីសំខាន់មួយចំនួនបានអះអាងថា ការអប់រំក្រៅប្រព័ន្ធ គឺជាគំរូចាស់មួយ ហើយការសិក្សាពេញមួយជីវិត គប្បីដាក់ឱ្យប្រើជំនួសវិញ។ ការអប់រំក្រៅប្រព័ន្ធ អាចនឹងលែងមានប្រសិទ្ធភាព បន្ទាប់ពីមានអនុវត្តការសិក្សាពេញមួយជីវិតនេះ ដោយសារតែយើងមិនគួរខ្វះខ្វាយពេលវេលារបស់យើងធ្វើការងារទៅលើគោលនយោបាយពីរផ្សេងគ្នាសម្រាប់រឿងតែមួយនោះឡើយ[8]*។

## ការផ្តល់ហិរញ្ញប្បទានដល់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា

បើតាមយុទ្ធសាស្ត្រកំណែទម្រង់ (២០១៨-២០២៣) ក្រសួងអប់រំ យុវជន និងកីឡា បានផ្តោតការយកចិត្តទុកដាក់ទៅលើការគ្រប់គ្រងការអប់រំសិក្សាធិការ ការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងធនធានមនុស្ស ទាំងអស់នេះគឺមានសារៈសំខាន់សម្រាប់ការលើកកម្ពស់ការអប់រំប្រកបដោយគុណភាព ដើម្បីសម្រេចបាននូវគោលដៅទី ២ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅត្រឹមឆ្នាំ២០៣០ (ហង់ ជួនណារ៉ុន, ២០១៨)។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា មានគោលដៅច្បាស់លាស់ ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន និងពេលអនាគត និងលទ្ធភាពប្រកួតប្រជែងរបស់ជាតិ ដើម្បីសម្រេចបានមហិច្ឆតារបស់ខ្លួន ដែលនេះអាស្រ័យលើអ្នកដែលមានចំណេះដឹង និងមានជំនាញពាក់ព័ន្ធ ដែលបង្ហាញពីកេរ្តិ៍ដំណែលវប្បធម៌ និងក្រមសីលធម៌របស់ប្រទេសជាតិ។ នៅក្នុងឆ្នាំ ២០០៦ ទឹកប្រាក់ប្រហែល ៩៤៦ លានដុល្លារអាមេរិក ត្រូវបានចំណាយដើម្បីជំរុញការអភិវឌ្ឍការអប់រំ ដែលទទួលបានពីរដ្ឋាភិបាល (៨០.៨%) ដៃគូអភិវឌ្ឍនានា (១៨.១%) និងប្រាក់កម្ចី (១.១%)។ យោងតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤-២០១៨ ក្រសួងអប់រំ យុវជន និងកីឡា បានវិនិយោគទឹកប្រាក់ចំនួន ៧៦៤ លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៦។ បន្ថែមលើនេះ ដៃគូអភិវឌ្ឍនានា រួមមានទីភ្នាក់ងារទ្វេភាគី និងពហុភាគី បានផ្តល់ប្រាក់ចំនួន ១៣៥.៨ លានដុល្លាអាមេរិកសម្រាប់ចូលរួមចំណែកដល់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ (២០១៤-២០១៨)។ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការបង្កើនកញ្ចប់ថវិកាប្រចាំឆ្នាំជាបន្តបន្ទាប់រហូតដល់ទឹកប្រាក់ ១,០៣៣ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៩ ទឹកប្រាក់ ១,៣៦៨ លានដុល្លារអាមេរិកក្នុងឆ្នាំ២០២៣ ទឹកប្រាក់ ១,៨០៤ លានដុល្លារអាមេរិកក្នុងឆ្នាំ ២០២៨ និងទឹកប្រាក់ចំនួន ១,៩៨៤ លានដុល្លារអាមេរិកក្នុងឆ្នាំ២០៣០។ ការវិនិយោគនេះអាចនឹងជួយរួមចំណែកដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេចបាននូវគោលបំណងផ្លាស់ប្តូរពីប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៣០ និងក្លាយជាប្រទេសអភិវឌ្ឍនៅត្រឹមឆ្នាំ២០៥០ (ក្រ.អយក, ២០១៤)។ ក្រៅពីជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ដៃគូអភិវឌ្ឍន៍បាន

[7] អតីតប្រធានប្រតិបត្តិអង្គការក្រៅរដ្ឋាភិបាលដែលមានឈ្មោះថា អង្គការភាពជាដៃគូកម្ពុជា (NEP) ទីក្រុងភ្នំពេញ។

[8] ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ក្រសួងអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ

ផ្តល់ប្រាក់ចំនួន ១០.៣% នៅក្នុងឆ្នាំ២០០៨ និងកើនឡើងដល់ចំនួនខ្ពស់បំផុត ១៤.១% ក្នុងឆ្នាំ២០១៦។ ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ក្នុងវិស័យអប់រំបានធ្លាក់ចុះមក ១១.០% នៅក្នុងឆ្នាំ ២០១៧ និងមកត្រឹម ៧.៤% តែប៉ុណ្ណោះនៅក្នុងឆ្នាំ២០១៨។ ជំនួសមកវិញ នូវប្រាក់កម្ចីវិស័យអប់រំបានកើនឡើងពី ៩.១០ លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៤ ទៅ ២៤ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៨។

ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ប្រាក់យ៉ាងច្រើនសម្រាប់ការគ្រប់គ្រងនៅតាមសាលារៀន ដើម្បីសម្រេចបាននូវការអប់រំកម្រិតមូលដ្ឋានរយៈពេល ៩ ឆ្នាំ (៧៦.១% នៃកញ្ចប់ថវិកាសរុបនៅក្នុងឆ្នាំ២០១៦)៖ សាលាបឋមសិក្សា (៤៨.៣%) សាលាមធ្យមសិក្សាបឋមភូមិ (១៨.៧%) និងមត្តេយ្យសិក្សា (៩.១%)។ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ (៩.៣%) និងកម្រិតឧត្តមសិក្សា (៩.២%) ក្រសួងអប់រំ បានផ្តល់ប្រាក់ដែលមានចំនួនសមមាត្រប្រហាក់ប្រហែលគ្នា។ ក៏ប៉ុន្តែ មានចំនួនទឹកប្រាក់ត្រឹម ២.៩% (ឬ ២២.១៦ លានដុល្លារសហរដ្ឋអាមេរិក) នៃចំនួនកញ្ចប់ថវិកាសរុបប្រចាំឆ្នាំតែប៉ុណ្ណោះ ដែលត្រូវបានផ្តល់ឱ្យសម្រាប់ការអប់រំក្រៅប្រព័ន្ធក្នុងឆ្នាំ ២០១៦។ សាស្ត្រាចារ្យមួយរូបនៅមហាវិទ្យាល័យអប់រំ បានសង្កេតឃើញថា នាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការធានាថាកុមារ យុវជន មនុស្សពេញវ័យ ជនទីទ័លក្រីក្រ និងជនដែលមានពិការភាពទាំងអស់ យល់ដឹងអំពីសិទ្ធិរបស់ពួកគេក្នុងការទទួលបានការអប់រំកម្រិតមូលដ្ឋាន និងការរៀនសូត្រពេញមួយជីវិត។ ប៉ុន្តែក្នុងចំណោមអ្នកទាំងនោះ មានមនុស្សតិចតួចណាស់ដែលទទួលបានជំនាញដែលអាចគាំទ្រពួកគេឱ្យទទួលបានជោគជ័យនៅក្នុងការស្វែងរកការងារសមរម្យបាន។ ការពឹងផ្អែកទៅលើដៃគូអភិវឌ្ឍន៍ និងកញ្ចប់ថវិកាមានកំណត់ពីរដ្ឋាភិបាល គឺជាមូលហេតុមួយចំនួននៅក្នុងចំណោមមូលហេតុទាំងនេះ[9] ។ ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៅក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការអំពាវនាវសុំឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតទៅលើការអប់រំក្រៅប្រព័ន្ធ តាមរយៈកញ្ចប់ថវិកាដែលផ្តល់ដោយរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នានា ដោយសារផ្នែកនេះពិតជាមានសារៈសំខាន់ណាស់ក្នុងការរួមចំណែកដល់ការសម្រេចបាននូវគោលដៅអប់រំនៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។

ការសិក្សាពេញមួយជីវិត ត្រូវបានដាក់បញ្ចូលទៅក្នុងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs) ដែលត្រូវសម្រេចឱ្យបាននូវចន្លោះឆ្នាំ២០១៥ ដល់ឆ្នាំ២០៣០ ហើយគោលដៅ SDG ទី ៤ គឺជាគោលដៅមួយក្នុងចំណោមគោលដៅទាំង ១៧ នេះ។ *ធានានូវការអប់រំដែលមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសនៃការសិក្សាពេញមួយជីវិតសម្រាប់មនុស្សទាំងអស់គ្នា។* ដោយសារការសិក្សាពេញមួយជីវិត គឺជាការប្តេជ្ញាចិត្តជាសាកល យើងនឹងដាក់បញ្ចូលវាទៅក្នុងយន្តការដែលមានស្រាប់។ គោលនយោបាយស្តីពីការសិក្សាពេញមួយជីវិត បច្ចុប្បន្ននេះត្រូវបានធ្វើសេចក្តីព្រាង និងរង់ចាំការអនុម័តសម្រេចដោយទីស្តីការគណៈរដ្ឋមន្ត្រី។ យើងបានរួមបញ្ចូលក្រសួងពាក់ព័ន្ធចំនួន ១៣ ឬ ១៤ ដើម្បីធ្វើការងារលើគំនិតផ្តួចផ្តើមនេះ។ យើងក៏ត្រូវធ្វើការយ៉ាងជិតស្និតជាមួយអង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដែលមានភាពសម្បូរបែបទាំងផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្ស។

[9] សាស្ត្រាចារ្យ មហាវិទ្យាល័យអប់រំ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ឧទាហរណ៍ មេរៀនដែលបានសិក្សារៀនសូត្រ និងការអនុវត្តប្រសើរបំផុតរបស់អង្គការក្រៅរដ្ឋាភិបាល គឺពិតជាមានសារៈប្រយោជន៍ណាស់ដើម្បីលើកកម្ពស់ការសិក្សាពេញមួយជីវិតនៅកម្ពុជា។ គោលនយោបាយនេះ នឹងអាចដំណើរការទៅបានល្អ ល្គឹកណាភាគីពាក់ព័ន្ធទាំងអស់ធ្វើការងាររួមគ្នា។ ការសិក្សាពេញមួយជីវិត គឺជាបញ្ហាអន្តរវិស័យមួយ [10] ។ កម្មវិធីមួយក្នុងចំណោមកម្មវិធីអាទិភាពទាំង ១២ ដែលបានស្នើឡើងដោយផែនការយុទ្ធសាស្ត្រវិស័យអប់រំ (២០១៤-២០១៨) បានរួមបញ្ចូលផងដែរនូវការសិក្សាពេញមួយជីវិតនេះ ហើយកម្មវិធីអាទិភាពទី ១០ ត្រូវបានបង្កើតឡើងដូចខាងក្រោម៖

> *កម្មវិធីអក្ខរកម្ម និងការសិក្សាពេញមួយជីវិត – កម្មវិធីសមមូលមួយចំនួន និងយន្តការដែលមានការកំណត់ច្បាស់លាស់សម្រាប់អក្ខរកម្ម និងការសិក្សាពេញមួយជីវិត ដើម្បីអនុញ្ញាតឱ្យធនធានមនុស្សរបស់ប្រទេសអាចសម្របខ្លួនជាបន្តបន្ទាប់ និងទទួលបានអត្ថប្រយោជន៍ពីឱកាសថ្មីៗនៅក្នុងមជ្ឈដ្ឋានសង្គម វប្បធម៌ និងសេដ្ឋកិច្ច* (ក្រ.អយក, ២០១៤, ទំ. ១៥)។

## ការធ្វើឱ្យផែនការជាតិស្តីពីការសិក្សាពេញមួយជីវិតក្លាយជាការពិត

ក្នុងអំឡុងពេលសម្អាស ប្រជាជនជឿជាក់ថា រយៈពេលនៃការសិក្សារបស់ពួកគេត្រូវបានបញ្ចប់ បន្ទាប់ពីពួកគេទទួលបានការងារធ្វើ។ ប៉ុន្តែពួកគេគិតគូរពីការត្រឡប់ទៅសាលារៀនវិញបន្ទាប់ពីចំណេះដឹងនិងជំនាញរបស់ពួកគេពុំអាចបំពេញបានតាមតម្រូវការ ដើម្បីសម្រេចបាននូវគោលដៅការងារដូចបានគ្រោងទុក។ បច្ចុប្បន្ននេះ ប្រជាជនជាច្រើនបានទទួលស្គាល់ពីសារៈសំខាន់នៃការអភិវឌ្ឍជំនាញវិជ្ជាជីវៈពេញមួយជីវិតរស់នៅរបស់ពួកគេ នៅពេលដែលពួកគេប្រឈមមុខនឹងឧបសគ្គ និងបញ្ហាប្រឈមនានានៅក្នុងការបំពេញការងាររបស់ពួកគេ។ គោលដៅចម្បងនៃការសិក្សាពេញមួយជីវិត គឺតម្រូវឱ្យប្រជាជនគិតថាការសិក្សាគឺជាសកម្មភាពមិនចេះចប់ និងត្រូវធ្វើការរៀនសូត្របន្ថែមនូវជំនាញ និងចំណេះដឹងផ្សេងៗ ដើម្បីសម្របតាមការផ្លាស់ប្តូរក្នុងសង្គម សេដ្ឋកិច្ច និងបច្ចេកវិទ្យា។ ការសិក្សាពេញមួយជិវិត នឹងផ្តល់អត្ថប្រយោជន៍ដល់បុគ្គលជាច្រើន ដោយសារភាពរីកចម្រើននៃជំនាញ គឺមានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងចំណេះដឹង និងជំនាញ។ ការផ្លាស់ប្តូរពីប្រភេទការងារមួយទៅប្រភេទការងារមួយទៀត តម្រូវឱ្យមានការសិក្សារៀនសូត្រជំនាញថ្មីៗ និងការកែលម្អចំណេះដឹងពាក់ព័ន្ធនឹងការងារនេះ ដើម្បីឱ្យមានសមត្ថភាពល្អប្រសើរជាងនេះ។ ពលរដ្ឋស្ទើរគ្រប់រូបនៅក្នុងប្រទេស បំពេញការងារដើម្បីជំរុញកំណើនសេដ្ឋកិច្ច។ រដ្ឋាភិបាល កំពុងបំពេញការងារដើម្បីជាមគ្គុទេសក៍ដឹកនាំការរៀនសូត្រសម្រាប់ប្រជាជនគ្រប់គ្នា។ ការសិក្សាពេញមួយជីវិត ជួយជំរុញកំណើនសេដ្ឋកិច្ច និងជួយប្រជាពលរដ្ឋឱ្យក្លាយជាពលរដ្ឋសាកល[11]។

សេចក្តីព្រាងនៃគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត ត្រូវបានបញ្ចប់ជាស្ថាពរ និងបានដាក់ជូនសម្រាប់ការអនុម័តសម្រេចនៅទីស្តីការគណៈរដ្ឋមន្ត្រី។ នៅចុងឆ្នាំ២០១៨ ឬឆ្នាំ២០១៩ តម្រូវឱ្យមានការចាត់វិធានការ

---

[10] អគ្គនាយកនៃអគ្គនាយកដ្ឋានផែនការ និងគោលនយោបាយ ក្រសួងអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ។

[11] ប្រធានផ្នែកអប់រំនៃអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃអង្គការសហប្រជាជាតិ (UNESCO) រាជធានីភ្នំពេញ។

ជាចាំបាច់ ដើម្បីឱ្យការសិក្សាពេញមួយជីវិតក្លាយជាការពិតបាន។ នៅចន្លោះឆ្នាំ២០០០ និង២០១៥ ប្រទេសកម្ពុជាបានអនុម័ត និងដាក់ឱ្យអនុវត្តនៅក្នុងប្រទេសនូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ (MDGs)។ គោលដៅមួយក្នុងចំណោមគោលដៅទាំង ៨ (គោលដៅទី ២) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១៥ សម្រាប់សម្រេចបាននូវការអប់រំកម្រិតបឋមសិក្សាជាសាកល។ បន្ទាប់ពីគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ប្រទេសកម្ពុជាបន្តប្តេជ្ញាចិត្តក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ទាំង ១៧។ នៅក្នុងគោលដៅទី ៤ នៃគោលដៅ SDGs ពិភពលោកបានប្តេជ្ញាចិត្តក្នុងការធានានូវការអប់រំដែលមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសនៃការសិក្សាពេញមួយជីវិតសម្រាប់មនុស្សទាំងអស់គ្នានៅចន្លោះឆ្នាំ ២០១៥ ដល់ឆ្នាំ ២០៣០ ហើយបច្ចុប្បន្ននេះ ប្រទេសកម្ពុជាបានបង្កើតគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត។ សំណួរដែលត្រូវពិចារណានោះគឺតើប្រទេសកម្ពុជាកំពុងដោះស្រាយបញ្ហាយ៉ាងពិតប្រាកដ ឬក៏គ្រាន់តែធ្វើតាមពាក្យដែលបង្កើតឡើងដោយអង្គការសហប្រជាជាតិតែប៉ុណ្ណោះ។ ការផ្លាស់ប្តូរ MDGs ទៅ SDGs ជាមួយនឹងប្រព័ន្ធអប់រំរបស់ខ្លួនដែលមានស្រាប់ នឹងក្លាយជាបន្ទុកធ្ងន់ធ្ងរសម្រាប់បរិបទប្រទេសកម្ពុជា ដោយសារកញ្ចប់ថវិការដ្ឋាភិបាលសម្រាប់ការអប់រំនៅមានកម្រិត ជាពិសេសសម្រាប់ការអនុវត្តការសិក្សាពេញមួយជីវិត។ ដើម្បីលើកកម្ពស់ការសិក្សាពេញមួយជីវិត តម្រូវឱ្យមានសកម្មភាពជាច្រើនសម្រាប់ជាអន្តរាគមន៍ ប៉ុន្តែគុណភាព និងសមធម៌គឺជាគន្លឹះដ៏សំខាន់។ ទោះបីជាការសិក្សាពេញមួយជីវិតគឺជាគោលគំនិតថ្មីមួយក៏ពិតមែនសម្រាប់ប្រទេសកម្ពុជា ក៏ប៉ុន្តែ ESP ដែលមានស្រាប់នោះ រួមបញ្ចូលនូវសមាសភាពគន្លឹះជាច្រើននៃទស្សនៈស្តីពីការសិក្សាពេញមួយជីវិតនេះ។ ការសិក្សាពេញមួយជីវិត មានចំណុចពីរ៖ ភាពបត់បែន និងការសិក្សារៀនសូត្រសម្រាប់ការងារសមរម្យ[12]។

នៅពេលដែលប្រជាជនមានលទ្ធភាពទាបក្នុងការបង់ប្រាក់សម្រាប់ការអប់រំផ្ទាល់ខ្លួនដែលមានចំនួនត្រឹម ២៣១ ដុល្លារម្នាក់ក្នុងមួយឆ្នាំ ការជួយគាំទ្រពីភ្នាក់ងាររដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា គឺពិតជាមានសារៈសំខាន់ដើម្បីនាំយកគាត់ត្រឡប់ទៅកាន់សាលារៀនវិញសម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ។ នៅក្នុងឆ្នាំ ២០១៦ ក្រសួងអប់រំ យុវជន និងកីឡា បានវិនិយោគទឹកប្រាក់ចំនួន ៧៦៤ លានដុល្លារលើវិស័យអប់រំ ដែលក្នុងនោះ ៩៤.៦% ជាកញ្ចប់ថវិកាជាតិដែលទទួលបានសម្រាប់ការអប់រំក្នុងប្រព័ន្ធ និងមានត្រឹមតែ ២.៩% ប៉ុណ្ណោះសម្រាប់ការអប់រំក្រៅប្រព័ន្ធ។ ពុំមានកញ្ចប់ថវិកាច្បាស់លាស់ដែលបង្ហាញពីខ្ទង់ដែលត្រូវផ្តល់ឱ្យសម្រាប់កម្មវិធីសិក្សាពេញមួយជីវិតឡើយ ប៉ុន្តែប្រាក់ទាំងនោះទំនងជាត្រូវស្ថិតក្នុងប្រភេទនៃការអប់រំក្រៅប្រព័ន្ធ។ ប្រសិនបើដូចនេះមែន ការសិក្សាពេញមួយជីវិតគឺគ្រាន់តែជាពាក្យសម្តី ដែលប្រទេសកម្ពុជាត្រូវយល់ស្របទៅតាមការប្តេជ្ញាចិត្តជាអន្តរជាតិតែប៉ុណ្ណោះ។ ជាមធ្យម ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) សម្រាប់វិស័យអប់រំ (២០០៨និង ២០១៨) និងប្រាក់កម្ចីវិស័យអប់រំ (២០១៤-២០១៨) មានចំនួន ១៣៥.៨ និង ១៤.៣ លានដុល្លារអាមេរិក។ ជំនួយទាំងនោះ មានភ្នាក់ងារទ្វេភាគីជាអ្នកផ្តល់ (ឧ.ទា. ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ (AusAID) ទីភ្នាក់ងារសហ

[12] អគ្គនាយកនៃអគ្គនាយកដ្ឋានផែនការ និងគោលនយោបាយ ក្រសួងអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ។

ប្រតិបត្តិការអន្តជាតិជប៉ុន (JICA) ទីភ្នាក់ងារសហប្រតិបត្តិការអន្តជាតិកូរ៉េ (KOICA) ទីភ្នាក់ងារពហុភាគី (ឧ.ទា. ទីភ្នាក់ងារពិសេសអង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (UNESCO) មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ ដែលជាទីភ្នាក់ងារពិសេសរបស់សហរដ្ឋអាមេរិក (UNICEF) និងអង្គការកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងស្ថាប័នអន្តរជាតិផ្សេងទៀត (ឧ.ទា. ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

ស្ថាប័នទ្វេភាគី ស្ថាប័នពហុភាគី និងស្ថាប័នអន្តរជាតិនានា បានផ្តល់មូលនិធិដល់សកម្មភាពនានារបស់ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលកំពុងបំពេញការងារនៅក្នុងសហគមន៍ ដើម្បីគាំទ្រដល់វិស័យអប់រំ។ ជាពិសេស ស្ថាប័នទាំងអស់នេះ ផ្តល់មូលនិធិយ៉ាងច្រើនដល់សកម្មភាពនានា ដែលអនុវត្តនៅក្នុងប្រទេសកម្ពុជា ដែលជាការរួមចំណែកមួយដល់ការប្តេជ្ញាចិត្តជាអន្តរជាតិ តួយ៉ាងដូចជាគោលដៅ MDGs និងគោលដៅ SDGs ជាដើម។ ក្នុងន័យនេះ កម្មវិធីសិក្សាពេញមួយជីវិត អាចនឹងធ្វើការងារបានល្អ នៅពេលដែលរដ្ឋាភិបាលកម្ពុជាផ្តល់ថវិកាបន្ថែមសម្រាប់សកម្មភាពទាំងនេះ លើសពីចំនួនដែលមាននាពេលបច្ចុប្បន្ននៅក្នុងការអប់រំក្រៅប្រព័ន្ធ។ កញ្ចប់ថវិកាដែលមាន គឺមានចំនួនតិចតួច និងពុំអាចដំណើរការបានល្អនៅក្នុងការគាំទ្រដល់សកម្មភាពជាច្រើន ដើម្បីលើកកម្ពស់ថ្នាក់អក្ខរកម្ម ការអភិវឌ្ឍជំនាញ និងការបណ្តុះបណ្តាលវិជ្ជាជីវៈនោះទេ។ កញ្ចប់ថវិកាជាតិដែលមានសម្រាប់កម្មវិធីការសិក្សាពេញមួយជីវិត នឹងមិនត្រឹមតែធានានូវនិរន្តរភាពនៃកម្មវិធីនេះសម្រាប់ប្រតិបត្តិការរយៈពេលវែងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយកាត់បន្ថយការពឹងអាស្រ័យលើអន្តរជាតិថែមទៀតផង។ នៅក្នុងឆ្នាំ ២០១៥ ប្រទេសកម្ពុជាត្រូវបានចាត់ចំណាត់ថ្នាក់ជាថ្មីជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបដោយក្រុមធនាគារពិភពលោក។ ប្រាក់ចំណូលដុលសរុប (GNI) ក្នុងម្នាក់មានចំនួន ១,០៧០ ដុល្លារសហរដ្ឋអាមេរិក។ ជាមួយនឹងគោលដៅចង់ផ្លាស់ប្តូរពីប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៣០ ហើយក្លាយជាប្រទេសអភិវឌ្ឍនៅត្រឹមឆ្នាំ២០៥០ ជំនួយអន្តរជាតិនឹងត្រូវកាត់បន្ថយជាស្វ័យប្រវត្តិ ហើយត្រូវជំនួសមកវិញដោយកញ្ចប់ថវិកាជាតិ។ ភាពប្រសើរឡើងនៃចំណេះដឹង និងជំនាញពាក់ព័ន្ធដែលឆ្លុះបញ្ចាំងពីមរតកវប្បធម៌ និងសីលធម៌នៃប្រទេសកម្ពុជា សម្រាប់កំណើនសេដ្ឋកិច្ច និងលទ្ធភាពប្រកួតប្រជែងនៃប្រទេសជាតិ នឹងត្រូវបានធានាដោយការវិនិយោគបន្ថែមតែប៉ុណ្ណោះ តាមរយៈការប្រើប្រាស់កញ្ចប់ថវិកាជាតិសម្រាប់លើកកម្ពស់ការអប់រំក្នុងប្រព័ន្ធ និងការអប់រំក្រៅប្រព័ន្ធ។

គំនិតយោបល់សម្រាប់ការធ្វើផែនការ និងការបកស្រាយគោលនយោបាយ

*បង្កើតក្របខណ្ឌផ្លូវច្បាប់ផ្អែកលើគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត។* បន្ទាប់ពីមានការអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបង្កើតអង្គភាពទទួលបន្ទុកការងារ ឬក្រុមការងារជាតិទទួលបន្ទុកកម្មវិធីសិក្សាពេញមួយជីវិត។ អង្គភាព ឬក្រុមការងារ ត្រូវធ្វើការងារលើក្របខណ្ឌផ្លូវច្បាប់ដូចជា ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រ និងផែនការសកម្មភាពនានា ដែលមានលក្ខណៈស្របគ្នាជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

***កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារអប់រំសម្រាប់ការផ្ទេរចំណេះដឹង និងជំនាញនៅទូទាំងប្រទេស។*** តាមរយៈការលើកកម្ពស់មុខងារ និងប្រតិបត្តិការមជ្ឈមណ្ឌលសិក្សានៅតាមសហគមន៍ វាអាចជួយលើកកម្ពស់ដល់ការផ្ទេរការអប់រំក្រៅប្រព័ន្ធ និងការអប់រំក្នុងប្រព័ន្ធ។ ប្រសិនបើអាចទៅរួច បរិក្ខារបច្ចេកវិទ្យា និងព័ត៌មានវិទ្យា ត្រូវបំពាក់ដើម្បីអាចឱ្យប្រជាពលរដ្ឋធ្វើការពង្រីកបន្ថែមនូវជំនាញនិងចំណេះដឹងរបស់ពួកគេ។

***បង្កើនការទទួលបានការអប់រំក្រៅផ្លូវការតាមរយៈបណ្តាញព័ត៌មានសង្គម។*** បច្ចុប្បន្ននេះ ប្រជាជនកម្ពុជាជាច្រើនអាចចូលទៅប្រើប្រាស់បណ្តាញព័ត៌មានសង្គមបានកាន់តែច្រើនឡើងៗ ដូចជា Facebook, Instagram, Telegram, WhatsApp និង YouTube ជាដើម។ កម្មវិធីទាំងអស់នេះ កំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការចែករំលែកចំណេះដឹង និងលើកកម្ពស់ជំនាញ និងសមត្ថភាព។

***បង្កើតយន្តការសម្របសម្រួល និងប្រព័ន្ធតាមដាននិងវាយតម្លៃការងារ។*** ដើម្បីធ្វើការតាមដានវឌ្ឍនភាពការងារ ត្រូវបង្កើតប្រព័ន្ធតាមដាននិងវាយតម្លៃការងារមួយ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា។ ប្រព័ន្ធ EMIS ដែលមានស្រាប់ គឺជាជម្រើសដ៏ល្អបំផុតមួយ។ រាល់សូចនាករទាំងអស់ដែលពាក់ព័ន្ធនឹងការសិក្សាពេញមួយជីវិត ត្រូវរួមបញ្ចូលក្នុងប្រព័ន្ធនេះ ដើម្បីតាមដានវឌ្ឍនភាពការងារសម្រាប់ការធ្វើរបាយការណ៍ និងការវាយតម្លៃ។ បន្ថែមលើនេះ EMIS មិនត្រឹមតែជួយកាត់បន្ថយថ្លៃចំណាយនៃការអនុវត្តការតាមដាននិងវាយតម្លៃការងារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានភាពស្របគ្នាជាមួយនឹង ESP និង NSDP ដែលមានស្រាប់ផងដែរ។

## ឯកសារយោង


CDC (2018) *Development Cooperation and Partnership Report*. Phnom Penh: Council for the Development of Cambodia.

Hang, C.R. (2018) Strategy for educational reform (2018-2023) Phnom Penh: Ministry of Education Youth and Sport.

MoEYS (2014) *Education Strategic Plan 2014-2018*. Phnom Penh: Ministry of Education Youth and Sport.

MoEYS (2016) *Education Strategic Plan 2014-2018*. Phnom Penh: Ministry of Education Youth and Sport.